ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ២៦៥ MOC / M 2003

*រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០០៣*

# ប្រកាស

## ស្តីពីការដាក់ឱ្យដេញថ្លៃលើកូតា សំលៀកបំពាក់ ដែលត្រូវនាំចេញទៅសហរដ្ឋអាមេរិក សំរាប់ប្រើប្រាស់ក្នុងឆ្នាំ២០០៣

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤/អនក្រ បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមសុពលភាពនៃការបន្ត កិច្ចព្រមព្រៀងពាណិជ្ជកម្មវាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌធ្វើពីកប្បាស ឡែន សរសៃសិប្បនិម្មិតធ្វើដោយដៃមនុស្ស សរសៃរុក្ខជាតិគ្មានជាតិកប្បាស និងសរសៃល្បាយសូត្ររវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលបានចុះហត្ថលេខា កាលពី ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០១
- បានឃើញការចាំបាច់របស់ក្រសួង

## <u>សំរេច</u>

<u>ប្រការ១</u>- គ្រប់រោងចក្រកាត់ដេរទាំងអស់ដែលកំពុងដំណើរការ និងដែលបានចុះបញ្ជី នៅនាយកដ្ឋានប្រពន្ធអនុគ្រោះពាណិជ្ជកម្ម (នាយកដ្ឋាន GSP ) នៃក្រសួងពាណិជ្ជកម្ម មុនថ្ងៃទី

១៧ ខែកញ្ញា ឆ្នាំ២០០៣ ត្រូវបានអញ្ជើញឱ្យមកដេញថ្លៃ តាមប្រភេទផ្សេងៗ នៃ **Quota** ទៅតាមលទ្ធភាពផលិតកម្មរបស់ខ្លួន ។

__**ប្រការ២**__- រោងចក្រនិមួយៗត្រូវបានអនុញ្ញាតឱ្យដេញថ្លៃ យកបរិមាណតិច ឬស្មើនឹងបរិមាណនៃកូតា ដែលដាក់ ឱ្យដេញថ្លៃ តាមប្រភេទនិមួយៗនៃ **Quota** ដូចតទៅ :

| **ប្រភេទ** | **បរិមាណដេញថ្លៃ (DZ)** | **ប្រភេទ** | **បរិមាណដេញថ្លៃ (DZ)** |
|---|---|---|---|
| ៣៣៤/៦៣៤ | ១៨,៧៦៣ | ៣៥២/៦៥២ | ៤៣,៣១៧ |
| ៣៣៥/៦៣៥ | ៤៥០ | ៤៣៥ | ២០,២៧៦ |
| ៣៣៨/៣៣៩ | ២៥០ | ៤៣៨ | ៣៧,៧៩២ |
| ៣៤០/៦៤០ | ២៦០,៤១៣ | ៤៤៥/៤៤៦ | ៩៥,០៨៣ |
| ៣៤៥ | ២០,៣៤៧ | ៦៣៨/៦៣៩ | ១៩៨,១៣៥ |
| ៣៤៧/៣៤៨/៦៤៧/៦៤៨ | ៦៩៦ | ៦៤៥/៦៤៦ | ៩៥,៩៦៤ |

__**ប្រការ៣**__- ពាក្យសុំដេញថ្លៃនីមួយៗ ត្រូវភ្ជាប់មកជាមួយនូវមូលប្បទានប័ត្រដែលមានការបញ្ជាក់ពីធនាគារ **Certified Check** ដែលមានតំលៃស្មើនឹង ១០% នៃតំលៃដេញថ្លៃសរុប ។ មូលប្បទានប័ត្រនេះ ត្រូវទូទាត់ប្រាក់ជូន គណកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ ( Export Quotas Management Committee " EQMC " ) ។ ការបង់ប្រាក់កក់អប្បបរមាមិនគ្រប់ចំនួន ១០% នៃតម្លៃដេញថ្លៃសរុបនឹងចាត់ទុកថា ពាក្យសុំដេញថ្លៃគ្មានប្រសិទ្ធភាព ។ ឧទាហរណ៍ រោងចក្រ **A**

ដេញថ្លៃ ចំនួន ២០ 000 ឡូ តំលៃ ៨ ដុល្លា/ឡូ = ១៦០,000 ដុល្លា

ទឹកប្រាក់កក់ ១០ % = ១៦,000 ដុល្លា

__**ប្រការ៤**__- ការដេញថ្លៃក្នុងតំលៃខ្ពស់បំផុតតាម **Category** នឹងបានទទួលជ័យជំនះ ។ Quota នឹងត្រូវបានបែងចែកដល់អ្នកដេញថ្លៃ ដែលបានទទួលជោគជ័យរហូតដល់បរិមាណ Quota សរុប ត្រូវបានបែងចែកអស់ ។

__**ប្រការ៥**__- **Quota** ដែលមិនទាន់បែងចែកនឹងបន្តទុកឱ្យអ្នកដេញថ្លៃក្រោយទៀត ។

**ប្រការ៦-** តំលៃនៃការចូលរួមដេញថ្លៃ នឹងត្រូវទទួលយក ចំពោះរាល់ការបន្ថែមចំនួនទសភាគ ២០ សេន ( ម្ភៃ ) នៃប្រាក់ដុល្លាសហរដ្ឋអាមេរិកលើ ថ្លៃឯកត្តាតាមប្រភេទ នីមួយៗ :

| | | | |
|---|---|---|---|
| Cat ៣៣៤/៦៣៤ | 3.00$/doz | Cat ៣៥២/៦៥២ | 0.60$/doz |
| Cat ៣៣៥/៦៣៥ | 3.00$/doz | Cat ៤៣៥ | 1.00$/doz |
| Cat ៣៣៨/៣៣៩ | 3.00$/doz | Cat ៤៣៨ | 1.00$/doz |
| Cat ៣៤០/៦៤០ | 0.80$/doz | Cat ៤៤៥/៤៤៦ | 0.50$/doz |
| Cat ៣៤៥ | 1.00$/doz | Cat ៦៣៨/៦៣៩ | 0.80$/doz |
| Cat ៣៤៧/៣៤៨/៦៤៧/៦៤៨ | 5.00$/doz | Cat ៦៤៥/៦៤៦ | 0.50$/doz |

**ប្រការ៧-** ពាក្យដេញថ្លៃត្រូវដាក់ជូន ឯកឧត្តមប្រធានគណៈកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ " EQMC " នៃក្រសួងពាណិជ្ជកម្ម ដែលមានទីតាំង នៅអគារជាន់ទី២ លេខ ២០ B មហាវិថីព្រះនរោត្តម ។ ពាក្យសុំដេញថ្លៃត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត ភ្ជាប់ជាមួយនូវមូលប្បទានប័ត្រ ដែលមានទឹកប្រាក់ចំនួន ១០ % នៃតំលៃដេញថ្លៃសរុប ដាក់ក្នុងស្រោមសំបុត្រនោះ ។

**ប្រការ ៨-** កាលបរិច្ឆេទនៃការបើកស្រោមសំបុត្រដេញថ្លៃ គឺនៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៣ ចាប់ពីម៉ោង ៨:០០ ព្រឹក នៅទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អគារលេខ ២០ អា ជាន់ទី២ មហាវិថីព្រះនរោត្តម ។

**ប្រការ ៩-** កាលបរិច្ឆេទឈប់ទទួលពាក្យដេញថ្លៃគឺនៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ វេលាម៉ោង ៥:០០ ល្ងាច ។

**ប្រការ ១០-** លទ្ធផលនៃការដេញថ្លៃ នឹងត្រូវប្រកាសជាសាធារណៈ នៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៣ តាមប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

**ប្រការ ១១-** អ្នកចូលរួមដេញថ្លៃ ដែលបានទទួលជោគជ័យ នឹងអាចប្រើប្រាស់កូតាបាន បន្ទាប់ពីបានទូទាត់តំលៃដេញថ្លៃ ដែលនៅសេសសល់ចំនួន ៩០ % រួចហើយ ។ កាលបរិច្ឆេទទូទាត់ចុងក្រោយ ត្រូវបានកំណត់ នៅថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៣ ។

**ប្រការ ១២-** អ្នកដេញថ្លៃដែលបានទទួលជោគជ័យ ប៉ុន្តែខកខានមិនបានទទួលយកកូតារបស់ខ្លួនទៅប្រើប្រាស់ នឹងត្រូវរិបអូសយកប្រាក់កក់ ១០% ហើយបរិមាណកូតានោះ នឹងបន្តទុក

សំរាប់ដេញថ្លៃលើកក្រោយទៀត ។ ក្រសួងពាណិជ្ជកម្មរក្សាសិទ្ធិក្នុងការ មិនអនុញ្ញាតឱ្យក្រុមហ៊ុននោះ ចូលរួមដេញថ្លៃកូតា លើកក្រោយៗទៀតឡើយ ។

**ប្រការ ១៣-** អ្នកចូលរួមដេញថ្លៃ ដែលមិនបានទទួលជោគជ័យ នឹងត្រូវបានផ្តល់ជូនវិញនូវប្រាក់កក់ ១០% របស់ខ្លួន ចាប់ពីថ្ងៃបន្ទាប់ពីថ្ងៃដេញថ្លៃតទៅ ។

**ប្រការ ១៤-** Quota ដែលបានទទួល តាមរយៈការដេញថ្លៃនេះ ប្រើប្រាស់បានសំរាប់ឆ្នាំសារពើពន្ធ ២០០៣ តែប៉ុណ្ណោះ ។

**ប្រការ ១៥-** ការសំរេចចិត្តរបស់ EQMC នៅក្នុងការអនុវត្តការដេញថ្លៃ ជាការសំរេចចុងក្រោយ ។

**ប្រការ ១៦-** នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានរដ្ឋបាល រាល់ផលិតករសំលៀកបំពាក់ និង សមាជិកគណៈកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ ត្រូវទទួលអនុវត្តនូវប្រការនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីស្តីទី

**ស៊ុយ សែម**

<u>ចំលងជូន:</u>

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

" ដើម្បីជ្រាបជាពតិមាន "

- ទូរទស្សន៍ជាតិ វិទ្យុជាតិ និងសារពត៌មានជាតិ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ